## កិច្ចធានាមានកំណត់សម្រាប់បរិក្ខារប្រើអម (Accessory)

បរិក្ខារប្រើអមដែលត្រូវផ្តល់ជូនលោកអ្នក សម្រាប់ប្រើជាមួយនឹងម៉ូឌែលផលិតផលកាន់ដៃ BlackBerry ជាក់លាក់ណាមួយរបស់លោកអ្នក (“**បរិក្ខារប្រើអម**”) គឺជាផលិតផលត្រូវបានធានាគុណភាព សម្រាប់រយៈពេលតិចជាង (ក) មួយ (១) ឆ្នាំគិតចាប់ពីថ្ងៃដែលបរិក្ខារប្រើអមនេះត្រូវបានទិញជាលើកដំបូងដោយលោកអ្នកក្នុងនាមជាអ្នកប្រើប្រាស់ដើម (original end-user) (“**លោកអ្នក**”) ហើយ (ខ) រយៈពេលធានានេះនឹងចប់នៅពេល : (១) អ្នកបំពាន ឬបញ្ឈប់កិច្ចព្រមព្រៀងអាជ្ញាប័ណ្ណកម្មវិធី (software)/អ្នកប្រើប្រាស់ (end user) ផលិតផល BlackBerry (“**កិច្ចព្រមព្រៀងអាជ្ញាប័ណ្ណ**”) ដែលត្រូវបានធ្វើឡើងដោយលោកអ្នក ជាមួយនឹងក្រុមហ៊ុន Research in Motion Limited និង/ឬក្រុមហ៊ុនសាខានានារបស់ក្រុមហ៊ុននេះ (**“RIM”**) ឬ (២) អ្នកបំពាន : (i) កិច្ចធានាមានកំណត់នេះ (ii) កិច្ចធានាមានកំណត់ដែលត្រូវផ្តល់ជូនជាមួយនឹងផលិតផលកាន់ដៃ BlackBerry (iii) កិច្ចធានាមានកំណត់ណាក៏ដោយដែលត្រូវបានផ្តល់ជូនជាមួយនឹងបរិក្ខារប្រើអម ឬថ្ម BlackBerry ណាមួយ ឬ (iv) ព័ត៌មានសុវត្ថិភាពដែលត្រូវបានផ្តល់ជូនជាមួយនឹងបរិក្ខារប្រើអម និង/ឬផលិតផលកាន់ដៃ BlackBerry (“**រយៈពេលធានា**”)។ កិច្ចធានាមានកំណត់នេះមិនអាចផ្ទេរបានឡើយ។ នៅក្នុងរយៈពេលនៃការធានា បរិក្ខារប្រើអមនេះនឹងត្រូវបានជួសជុល ឬប្តូរថ្មីជូនអាស្រ័យតាមការសម្រេចចិត្តរបស់ក្រុមហ៊ុន RIM ដោយមិនគិតប្រាក់ពីលោកអ្នក សម្រាប់ទាំងថ្លៃបរិក្ខារប្តូរថ្មីជូន និងថ្លៃបំរើសេវា។ ប្រសិនបើបរិក្ខារប្រើអមត្រូវបានជួសជុល ឬប្តូរថ្មីជូននៅក្នុងរយៈពេលធានា រយៈពេលធានានេះនឹងផុតកំណត់ក្នុងរយៈពេល ៩១ថ្ងៃក្រោយពីការជួសជុល ឬការប្តូរថ្មីជូន បើហេតុការណ៍មិនកើតឡើងដូច្នេះទេ រយៈពេលធានានេះនឹងផុតកំណត់ក្នុងរយៈពេលមួយឆ្នាំ បន្ទាប់ពីថ្ងៃទិញជាលើកដំបូង។ ផ្អែកតាមកិច្ចព្រមព្រៀងរវាងក្រុមហ៊ុន RIM និងក្រុមហ៊ុនលក់បន្ត ឬក្រុមហ៊ុនចែកចាយដែលអ្នកបានទិញបរិក្ខារប្រើអម និង/ឬ BlackBerry Solution (“**ក្រុមហ៊ុនផ្តល់ Solution របស់ RIM**”) កិច្ចធានាមានកំណត់នេះ នៅក្នុងរយៈពេលធានា នឹងត្រូវបានគោរពអនុវត្តតាមដោយក្រុមហ៊ុន RIM ឬក្រុមហ៊ុនផ្តល់ Solution របស់ RIM។ កិច្ចធានាមានកំណត់នេះមិនធានាចំពោះករណីសឹករិចរិល និងបែកបាក់តាមធម្មជាតិឡើយ ឬប្រសិនបើបរិក្ខារប្រើអម ឬបរិក្ខារបង្គុំណាមួយរបស់បរិក្ខារប្រើអមនេះត្រូវបានបើក ឬជួសជុលដោយបុគ្គលណាមួយដែលមិនបានទទួលការអនុញ្ញាតពីក្រុមហ៊ុន RIM ហើយកិច្ចធានាមានកំណត់នេះក៏មិនរ៉ាប់រងការជួសជុល ឬប្តូរបរិក្ខារប្រើអមថ្មីជូន ចំពោះបរិក្ខារប្រើអមណាមួយដែលខូចខាតដោយសារ : ការប្រើប្រាស់ខុស (misuse) សំណើមឬវត្ថុរាវ ការដាក់ជិតឬដាក់ហាលកម្តៅ គ្រោះថ្នាក់ ការប្រើប្រាស់មិនបានត្រឹមត្រូវ (abuse) ការធ្វេសប្រហែស ការប្រើប្រាស់ខុសមុខងារ (misapplication) ឬការខូចខាតកើតពីការជួសជុល ឬការកែប្រែដោយបុគ្គលណាម្នាក់ក្រៅពីក្រុមហ៊ុន RIM។ កិច្ចធានាមានកំណត់នេះមិន

រ៉ាប់រងការខូចខាតទៅលើផ្ទៃរបស់បរិក្ខារប្រើអមឡើយ។ កិច្ចធានាមានកំណត់នេះមិនធានាចំពោះបរិក្ខារផ្សេងទៀត ក្រៅតែពីបរិក្ខារប្រើអម។ កិច្ចធានាមានកំណត់នេះក៏មិនធានាផងដែរ ប្រសិនបើដំណើរការមិនប្រក្រតីកើតចេញពីការប្រើប្រាស់បរិក្ខារប្រើអមជាមួយនឹងបរិក្ខារប្រើអមដទៃទៀត ផលិតផល សេវាកម្ម បរិក្ខារជំនួយ ឬបរិក្ខារបន្ទាប់បន្សំដែលមិនបានទទួលការគាំទ្រដោយច្បាស់លាស់ ឬមិនត្រូវបានផ្តល់ជូនដោយក្រុមហ៊ុន RIM និងនៅក្នុងករណីដែលក្រុមហ៊ុន RIM កំណត់ថា ដំណើរការមិនប្រក្រតីរបៀបនេះមិនមែនកើតចេញពីបរិក្ខារប្រើអមនេះឡើយ។ ជាងនេះទៀត ប្រសិនបើដំណើរការមិនប្រក្រតីកើតចេញពីការណ៍ដែលអ្នកប្រើប្រាស់ខកខានមិនបានអនុវត្តតាមព័ត៌មានសុវត្ថិភាព (Safety Information) ដែលត្រូវបានផ្តល់ជូនជាមួយនឹងបរិក្ខារប្រើអមនេះ ឬបរិក្ខារបង្គុំណាមួយរបស់ BlackBerry Solution ដែលរួមមានផលិតផលកាន់ដៃ BlackBerry, បរិក្ខារប្រើអមរបស់ BlackBerry មួយចំនួន រួមមានថ្ម និងស៊ីមកាត, BlackBerry Desktop Software ព្រមទាំងសេវាទិន្នន័យឥតខ្សែ និងឯកសារដែលពាក់ព័ន្ធ (**“BlackBerry Solution”**) ដូច្នេះ កិច្ចធានាមានកំណត់នេះអាចទុកជាមោឃៈ ហើយប្រសិនបើវាមិនត្រូវបានចាត់ទុកជាមោឃៈទេ វាក៏នៅតែមិនធ្វើការធានាជាដដែល។ **សូមអានឯកសារដែលត្រូវបានផ្តល់ជូនជាមួយនឹងបរិក្ខារប្រើអមនេះ ដើម្បីបានជ្រាបពីសេចក្តីណែនាំអំពីរបៀបទទួលបានកិច្ចគាំទ្រសម្រាប់អតិថិជន សម្រាប់បរិក្ខារប្រើអមរបស់លោកអ្នក ។**

ការជួលជុល ឬការប្តូរថ្មីជូនណាក៏ដោយដែលស្របតាមកិច្ចធានាមានកំណត់នេះ អាចត្រូវបានស្នើឡើងដោយលោកអ្នកទៅកាន់ក្រុមហ៊ុនផ្តល់ Solution របស់ RIM ។

ការជួសជុល ឬការប្តូរបរិក្ខារប្រើអមថ្មីជូន ដូចមានចែងនៅក្នុងកិច្ចធានាមានកំណត់នេះ គឺជាសំណងជំងឺចិត្តដែលផ្តល់ជូនសម្រាប់តែលោកអ្នកប៉ុណ្ណោះ។ ក្នុងកម្រិតអតិបរមាដែលអនុញ្ញាតដោយច្បាប់ពាក់ព័ន្ធនៅក្នុងដែនយុត្តាធិការរបស់លោកអ្នក កិច្ចធានាមានកំណត់នេះត្រូវបានប្រើជំនួសអោយការធានា សេចក្តីអនុញ្ញាតផ្លូវការ ការសន្យា ឬលក្ខខណ្ឌប្រភេទដទៃទៀតទាំងអស់ដែលត្រូវបានបង្ហាញ ឬមិនត្រូវបានបង្ហាញ រួមមាន តែមិនកំហិតត្រឹមរាល់ការធានា សេចក្តីអនុញ្ញាតផ្លូវការ ការសន្យា ឬលក្ខខណ្ឌនានាស្តីពីសិទ្ធិកាន់កាប់ ស្តីពីការសន្យាមិនខកខានគោរពច្បាប់ ស្តីពីភាពសក្តិសមសម្រាប់គោលបំណងឬការប្រើប្រាស់ជាក់លាក់ណាមួយ ស្តីពីភាពមានគុណភាពខ្ពស់អាចទិញលក់បាន ស្តីពីគុណភាពអាចទិញលក់បាន ស្តីពីគុណភាពគួរអោយពេញចិត្ត ស្តីពីភាពអាចប្រើប្រាស់បានយូរ ឬរាល់ការធានា សេចក្តីអនុញ្ញាតផ្លូវការ ការសន្យា ឬលក្ខខណ្ឌនានាដែលកើតចេញពីលក្ខន្តិកៈ ឬការអនុវត្តជាប្រពៃណី ឬប្រតិបត្តិការឬការប្រកបពាណិជ្ជកម្ម តាមរយៈកិច្ចធានានេះ ត្រូវបានដកចេញ។ ដែនយុត្តាធិការមួយចំនួនប្រហែលជាមិនអនុញ្ញាតអោយមានការដកចេញ ឬការដាក់កំហិតចំពោះការធានា

សេចក្តីអនុញ្ញាតផ្លូវការ ការសន្យា ឬលក្ខខណ្ឌរបៀបនេះឡើយ ។ ក្នុងកម្រិតដែលច្បាប់អនុញ្ញាតយ៉ាងពេញលេញ ការធានា សេចក្តីអនុញ្ញាតផ្លូវការ ការសន្យា ឬលក្ខខណ្ឌរបៀបនេះដែលពាក់ព័ន្ធនឹងបរិក្ខារប្រើអមនេះក្នុងកម្រិតមួយដែលពួកវាមិនអាចត្រូវបានដកចេញ គឺត្រូវបានកំហិតត្រឹមការជួសជុល ឬការប្តូរបរិក្ខារប្រើអមថ្មីជូន ដូចបានកំណត់ក្នុងកិច្ចធានាមានកំណត់នេះ ។ ទាំងក្រុមហ៊ុន **RIM** និងក្រុមហ៊ុនផ្តល់ **Solution** របស់ **RIM** ទោះបីយ៉ាងណាក៏ដោយ មិនត្រូវទទួលខុសត្រូវចំពោះលោកអ្នក ហើយលោកអ្នក តាមរយៈកិច្ចធានាមានកំណត់នេះ ត្រូវលះបង់មិនទាមទារសំណងមិនផ្ទាល់ **(indirect damges)** សំណងសេដ្ឋកិច្ច សំណងពិសេស **(special damages)** សំណងពាណិជ្ជកម្ម សំណងបន្ទាប់បន្សំ **(incidental damges)** សំណងទូទាត់សម្រាប់ប្រដៅ **(exemplary damges)** សំណងមិនចំពោះ **(consequential damages)** (រាប់បញ្ចូលទាំង តែមិនកំហិតត្រឹមការខាតបង់ផលចំណេញ ការខាតបង់ផលចំណូលអាជីវកម្ម ការបាត់បង់ ទិន្នន័យ ការខូចខាតបណ្តាលពីការយឺតយ៉ាវ ឬការមិនអាចថតទុក **(save)** នូវឯកសារដែលចង់រក្សាទុក និងឧប្បត្តិហេតុស្រដៀងគ្នានេះ និងសំណងរបួសបុគ្គល សំណងមរណៈភាពបុគ្គលដោយអំពើធ្វេសប្រហែសឬអាក្រក់ **(wrongful death)**) ដែលកើតចេញពី ឬទាក់ទិននឹងការប្រើប្រាស់ ឬការបំពេញមុខងាររបស់បរិក្ខារប្រើអមនេះ ទោះបីជាក្រុមហ៊ុន **RIM** ឬក្រុមហ៊ុនផ្តល់ **Solution** របស់ **RIM** ណាមួយ បានដឹងពីការអាចកើតមានឡើងនូវសំណងរបៀបនេះក៏ដោយ ។ ការដាក់កំហិតនេះមានបំណងអនុវត្តចំពោះ និងពិតជាអនុវត្តចំពោះសំណងទាំងនេះ ដោយមិនគិតថាសំណងទាំងនោះត្រូវបានប្តឹងទាមទារ ត្រូវបានអះអាងថាពិត **(asserted)** ឬត្រូវបានប្តឹងផ្តល់ ឬត្រូវបានទាមទារដោយសំអាងថាជាកំហុសរដ្ឋប្បវេណី (រាប់ទាំងការធ្វេសប្រហែស) ឬដោយផ្អែកលើកិច្ចសន្យា ឬនៅក្រោមកិច្ចធានា ឬនៅក្រោមច្បាប់ដទៃទៀតណាមួយឬទម្រង់សកម្មភាពណាក៏ដោយ ។ ពុំមានករណីណាដែលក្រុមហ៊ុន **RIM** ត្រូវទទួលខុសត្រូវចំពោះលោកអ្នក ឬចំពោះភាគីទីបីណាមួយដែលប្តឹងទាមទារតាមរយៈលោកអ្នក ឬតាងនាមអោយលោកអ្នក នូវសំណងដែលមានតម្លៃលើសពីតម្លៃទិញបរិក្ខារប្រើអមដែលអ្នកបានទិញនេះ ឬលើសពីតម្លៃប្តូរបរិក្ខារថ្មីជូន ទោះបីជាតម្លៃណាមួយខ្ពស់ជាងក៏ដោយ ។

ការបដិសេធមិនទទួលខុសត្រូវចំពោះកាតព្វកិច្ចណាមួយរបស់ក្រុមហ៊ុន RIM មិនអាចចាត់ទុកថាជាការការបដិសេធមិនទទួលខុសត្រូវចំពោះកាតព្វកិច្ចនោះជាប់រហូតឡើយ ឬមិនអាចចាត់ទុកថាជាការបដិសេធមិនទទួលខុសត្រូវចំពោះកាតព្វកិច្ចដទៃទៀតឡើយដែរ ។

កិច្ចធានាមានកំណត់នេះត្រូវបានគ្រប់គ្រងដោយ និងបកស្រាយតាមច្បាប់របស់ខេត្តអង់តារីយ៉ូ (Ontario) ប្រទេសកាណាដា វៀរលែងតែប្រភេទច្បាប់ណាដែលគ្រប់គ្រងការប្រឆាំងគ្នា/ខ្វែងគ្នានៃច្បាប់ (body of law

governing conflicts of law)។ ភាគីទាំងអស់នៃកិច្ចធានាមានកំណត់នេះ (ដែលអាចហៅរួមគ្នាថា "បណ្តាភាគី" និងហៅដោយឡែកថា "ភាគី") ព្រមព្រៀងថា អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីកិច្ចសន្យាលក់ទំនិញជាអន្តរជាតិ តាមរយៈកិច្ចធានាមានកំណត់នេះ ត្រូវបានដកចេញទាំងស្រុងពីការអនុវត្តរបស់កិច្ចធានាមានកំណត់នេះ។ រាល់ការខ្វែងគំនិតគ្នា និងវិវាទទាំងអស់ដែលកើតចេញពី ឬទាក់ទិននឹងកិច្ចធានាមានកំណត់នេះ នឹងត្រូវកាត់សេចក្តីជាស្ថាពរដោយការធ្វើមជ្ឈត្តកម្ម។ សេចក្តីសម្រេចរបស់មជ្ឈត្តករគឺជាសេចក្តីសម្រេចលើកចុងក្រោយបង្អស់ និងត្រូវតែគោរពអនុវត្តតាមដោយភាគីទាំងអស់ (លើកលែងតែសេចក្តីសម្រេចនោះត្រូវបានរកឃើញថាមានកំហុសដោយប្រត្យក្ស)។ សេចក្តីសម្រេចរបស់មជ្ឈត្តករត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវមានបញ្ជាក់ហេតុផលនានា។ សេចក្តីសម្រេចរបស់មជ្ឈត្តករត្រូវបង្គាប់អោយបង់ថ្លៃមជ្ឈត្តកម្មដោយភាគីទាំងអស់ដោយជួយចេញគ្នាក្នុងចំណែកណាមួយដែលមជ្ឈត្តករនោះសម្រេចថាសមរម្យ។ ប្រសិនបើមិនត្រូវបានហាមឃាត់ដោយច្បាប់នៃដែនយុត្តាធិការរបស់លោកអ្នក ការធ្វើមជ្ឈត្តកម្មត្រូវធ្វើឡើងនៅ : (i) ខេត្តអង់តារីយ៉ូ ប្រទេសកាណាដា (ii) កាត់សេចក្តីក្រោមច្បាប់របស់ខេត្តអង់តារីយ៉ូ (iii) ដំណើរការកាត់សេចក្តីដោយប្រើភាសាអង់គ្លេស (iv) កាត់សេចក្តីនៅក្រោមបញ្ញត្តិស្តីពីមជ្ឈត្តកម្មនៃសភាពាណិជ្ជកម្មអន្តរជាតិ ("**បញ្ញត្តិ**") និង (v) ត្រូវបានបើកសវនការដោយមជ្ឈត្តករមួយរូបដែលត្រូវបានតែងតាំងស្របតាមបញ្ញត្តិដូចបានពោលមកនេះ និងដែលត្រូវបានព្រមព្រៀងទទួលយកដោយភាគីទាំងអស់នៅក្នុងរយៈពេល ៣០ ថ្ងៃគិតចាប់ពីថ្ងៃតែងតាំងមជ្ឈត្តករនោះ នៅក្នុងករណីមិនអាចធ្វើដូច្នេះបាន ភាគីអព្យាក្រឹត្យមួយត្រូវតែងតាំងមជ្ឈត្តករ។ ប្រសិនបើបទបញ្ញត្តិនានានៃឈ្មោះខាងដើមនេះត្រូវបានហាមឃាត់ដោយច្បាប់នៅក្នុងដែនយុត្តាធិការរបស់លោកអ្នក ការធ្វើមជ្ឈត្តកម្មត្រូវ : (i) ធ្វើឡើងក្នុងប្រទេសសិង្ហបូរី (ii) កាត់សេចក្តីដោយមជ្ឈត្តកម្មស្របតាមបញ្ញត្តិស្តីពីមជ្ឈត្តិកម្មនៃមជ្ឈមណ្ឌលមជ្ឈត្តកម្មអន្តរជាតិសិង្ហបូរី (**"SIAC"**) ដែលនៅជាធរមាន ដែលបញ្ញត្តិទាំងនេះត្រូវបានចាត់ទុកថាត្រូវបានដាក់បញ្ចូលជាឯកសារយោងនៅក្នុងវាក្យខណ្ឌនេះ។ ការកាត់សេចក្តីត្រូវមានសមាសភាពមជ្ឈត្តករម្នាក់ដែលត្រូវបានតែងតាំងដោយប្រធានរបស់ SIAC ។ ភាសាសម្រាប់ធ្វើមជ្ឈត្តកម្មគឺភាសាអង់គ្លេស ។ គ្មានវិវាទណាមួយរវាងភាគីទាំងអស់ ឬដែលពាក់ព័ន្ធនឹងបុគ្គលណាម្នាក់លើកលែងតែលោកអ្នក អាចត្រូវភ្ជាប់បញ្ចូលគ្នា ឬដាក់បញ្ចូលគ្នាដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីក្រុមហ៊ុន RIM ឡើយ។

ប្រសិនបើបញ្ញត្តិមួយនៃកិច្ចធានាមានកំណត់នេះត្រូវបានចាត់ទុកថាអសុពលភាព ឬមិនអាចអនុវត្តបាន អសុពលភាព និងភាពមិនអាចអនុវត្តបានរបៀបនេះនឹងមិនធ្វើអោយមានអសុពលភាព ឬភាពមិនអាចអនុវត្តបានចំពោះកិច្ចធានាមានកំណត់ទាំងមូលនេះបានឡើយ ប៉ុន្តែ (ប្រសិនបើការពិចារណាមិនបានជិតដល់បានបង្កអោយមានបញ្ហាដូច្នេះកើតឡើង) កិច្ចធានាមានកំណត់នេះនឹងត្រូវបានបកស្រាយហាក់បីដូចជាពុំមានបញ្ញត្តិមួយ ឬច្រើន

ដែលគ្មានសុពលភាព ឬមិនអាចអនុវត្តបាននោះ ហើយសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនីមួយៗនឹងត្រូវបានបកស្រាយ និងអនុវត្តទៅតាមនោះផងដែរ។

ប្រសិនបើកិច្ចធានាមានកំណត់នេះត្រូវបានបកប្រែជាភាសាផ្សេងក្រៅពីភាសាអង់គ្លេស ច្បាប់ជាភាសាអង់គ្លេសនឹងត្រូវបានយកជាគោលប្រសិនបើកើតមានការខ្វែងគំនិតគ្នា ឬភាពខុសគ្នាទៅលើអត្ថន័យរវាងច្បាប់ជាភាសាអង់គ្លេស និងច្បាប់ដែលត្រូវបានបកប្រែជាភាសាផ្សេងនោះ ។

ប្រសិនបើមានភាពមិនស្របគ្នារវាងកិច្ចធានាមានកំណត់នេះ និងកិច្ចធានាដទៃទៀតដែលមាននៅក្នុងប្រអប់ដាក់បរិក្ខារប្រើអមនេះ ពេលនោះបញ្ញត្តិនៃកិច្ចធានាមានកំណត់នេះនឹងត្រូវបានយកទៅអនុវត្តចំពោះភាពមិនស្របគ្នានោះ។

**សេចក្តីក្រើនរំលឹក :** បរិក្ខារប្រើអមនេះគឺសម្រាប់ប្រើ**តែជាមួយនឹង**ផលិតផលកាន់ដៃ BlackBerry ដែលត្រូវគ្នាប៉ុណ្ណោះ។ សូមអានសៀវភៅណែនាំពីការតម្លើងនិងការប្រើប្រាស់ ឬសៀវភៅណែនាំអំពីការប្រើប្រាស់ដែលពាក់ព័ន្ធដើម្បីកំណត់ថាតើ បរិក្ខារប្រើអមនេះអាចប្រើប្រាស់បានជាមួយនឹងផលិតផលកាន់ដៃ BlackBerry របស់លោកអ្នកឬទេ។ ការប្រើប្រាស់តាមបែបផ្សេងៗទៀត នឹងធ្វើអោយមោឃៈដល់កិច្ចធានាមានកំណត់សម្រាប់បរិក្ខារប្រើអមនេះ ហើយក្រុមហ៊ុន RIM ទោះបីយ៉ាងណាក៏ដោយ មិនត្រូវទទួលខុសត្រូវចំពោះលោកអ្នក ឬចំពោះភាគីទីបីណាមួយ ចំពោះការខូចខាតទាំងឡាយណាដែលលោកអ្នក ឬភាគីទីបីណាមួយអាចទទួលរង ដោយសារតែការប្រើប្រាស់បរិក្ខារប្រើអមនេះជាមួយនឹងឧបករណ៍ ឬបរិក្ខារប្រើអមណាមួយដែលមិនមែនជាផលិតផលកាន់ដៃ BlackBerry ដែលត្រូវប្រើជាមួយ។

© 2008 ក្រុមហ៊ុន Research In Motion Limited។ រក្សាសិទ្ធិគ្រប់បែបយ៉ាង។ ម៉ាក រូបភាព និងនិមិត្តរូបរបស់ BlackBerry និងរបស់ក្រុមផលិតផលដទៃទៀតរបស់ក្រុមហ៊ុន RIM គឺជាកម្មសិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន Research In Motion Limited។ និមិត្តរូបរបស់ RIM របស់ Research In Motion របស់ "Always On, Always Connected" របស់ "envelope in motion" និងរូបសញ្ញារបស់ BlackBerry ត្រូវបានចុះបញ្ជីនៅការិយាល័យប៉ាតង់ និងម៉ាកសហរដ្ឋអាមេរិក និងនឹងត្រូវបាន ឬត្រូវបានចុះបញ្ជីនៅក្នុងប្រទេសដទៃទៀត។ រាល់ម៉ាក (brand) ឈ្មោះផលិតផល ឈ្មោះក្រុមហ៊ុន ម៉ាក និងម៉ាកសេវាដទៃទៀតទាំងអស់ គឺជាកម្មសិទ្ធិរបស់ក្រុមហ៊ុនកម្មសិទ្ធិកររបស់ពួកវារៀងៗខ្លួន។ កម្មវិធីសម្រាប់ផលិតផលកាន់ដៃ (handheld software) និង/ឬកម្មវិធីពាក់ព័ន្ធ (associated software) ត្រូវបានការពារដោយច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ សន្ធិសញ្ញាអន្តរជាតិ និងប៉ាតង់ផ្សេងៗ ដោយរាប់បញ្ចូលប៉ាតង់សហរដ្ឋអាមេរិកមួយ ឬច្រើនដូចតទៅ

នេះ ៖ 6,278,442; 6,271,605; 6,219,694; 6,075,470; 6,073,318; D,445,428; D,433,460; D,416,256 ។ ប៉ាតង់ដទៃទៀតត្រូវបានចុះបញ្ជី ឬនឹងត្រូវចុះបញ្ជីនៅក្នុងប្រទេសដទៃទៀតនៅជុំវិញពិភពលោក។ សូមបើកមើលវែបសាយ www.rim.net/patents.shtml ដើម្បីមើលបញ្ជីឈ្មោះប៉ាតង់បច្ចុប្បន្នដែលពាក់ព័ន្ធ។